នៅពេលដែលនរណាម្នាក់បាត់បង់ជីវិត

# ដំណើរការវះពិនិត្យសពដោយមន្ទីរពេទ្យ

ព័ត៌មានសំរាប់គ្រួសារនិងមិត្តភក្តិ


ក្រសួងសេវាកម្មពលរដ្ឋ
**(DEPARTMENT OF HUMAN SERVICES)**

រដ្ឋាភិបាល
នៃរដ្ឋអូស្រ្តាលីខាងត្បូង

# បញ្ជីរឿង


សេចក្តីផ្តើម 2

តើការវះពិនិត្យសពគឺជាអ្វីទៅ ? 3

*គំរោងពេលវេលាសំរាប់វះពិនិត្យសព*

តើអ្វីទៅដែលជាប្រយោជន៏នៃការវះពិនិត្យសព ? 4

នរណាទៅដែលសំរេចថា គួរតែមានការវះពិនិត្យសពនោះ ? 5

*ការវះពិនិត្យសពសំរាប់ការស៊ើបអង្កេត*

*ការវះពិនិត្យសពដោយមន្ទីរពេទ្យ*

នរណាទៅដែលផ្តល់ការអនុញ្ញាតសំរាប់ការវះពិនិត្យសព ? 7

តើមានជំរើសផ្សេងពីការវះពិនិត្យសពទាំងស្រុងឬទេ ? 8

តើមានលទ្ធភាពធ្វើអំណោយសរីរាង្គឬជាលិកាសំរាប់ការវះកាត់ផ្សាំឬទេ ? 9

តើមានការរក្សាទុកសរីរាង្គឬជាលិកាណាមួយ ក្រោយពីការវះពិនិត្យសពឬទេ ? 10

*សរីរាង្គឬជាលិកាដែលរក្សាទុកសំរាប់ការស្រាវជ្រាវនិងការសិក្សាអប់រំ*

តើអ្វីទៅដែលជាជំរើសសំរាប់ការប្រគល់មកវិញឬការបោះចោលសរីរាង្គ ? 11

តើខ្ញុំស្វែងដឹងនូវលទ្ធផលនៃការវះពិនិត្យសព តាមរបៀបណា ? 12

តើការរៀបចំពិធីឈាបនកិច្ច អាចធ្វើទៅនៅពេលណា ? 13

តើលោកអ្នកអាចទទួលជំនួយអ្វីខ្លះទៅ ? 14

*ជំនួយវប្បធម៌ និង សាសនា*

*ព័ត៌មានជាភាសាផ្សេងទៀត*

*វត្ថុអនុស្សាវរីយ៍*

*ព័ត៌មាននិងជំនួយសំរាលការសោកសង្រេង*

# សេចក្ដីផ្ដើម

កូនសៀវភៅនេះ បានត្រូវរៀបចំឡើងដើម្បីផ្ដល់ព័ត៌មានអំពីការវះពិនិត្យសពដោយមន្ទីរពេទ្យ។ កូនសៀវភៅនេះពន្យល់អំពីអ្វីទៅដែលជាការវះពិនិត្យសព មូលហេតុដែលគេពិចារណាថាទង្វើនេះមានសារសំខាន់ និងជំរើសទាំងពួងដែលលោកអ្នកអាចធ្វើ។ លោកអ្នកមានសិទ្ធិមិនចង់ដឹង និង មិនចង់ធ្វើជំរើស។

បើលោកអ្នកចង់ដឹងថែមទៀត យើងសូមឲ្យលោកអ្នកអានសៀវភៅនេះ មុនពេលធ្វើសេចក្ដីសំរេចណាមួយ។ បើលោកអ្នកយល់ព្រមនឹងការវះពិនិត្យសព លោកអ្នកនឹងត្រូវបំពេញក្រដាសស្នាមមួយ ដែលនឹងផ្ដល់ជូនលោកអ្នក។

គេជាច្រើនយល់ថា នេះជាពេលដ៏លំបាកដើម្បីធ្វើសេចក្ដីសំរេចចិត្ត។ បើលោកអ្នកមានសំណួរណាមួយ លោកអ្នកគួរសាកសួរបុគ្គលិកមន្ទីរពេទ្យ ដែលពិភាក្សាការវះពិនិត្យសពជាមួយលោកអ្នក។ ជាញឹកញាយ វាជាការមានប្រយោជន៍ក្នុងការពិភាក្សាជាមួយគ្រួសារលោកអ្នក វេជ្ជបណ្ឌិតលោកអ្នក ឬនរណាមួយដែលជិតស្និទ្ធនឹងលោកអ្នក។

# តើការវះពិនិត្យសពគឺជាអ្វីទៅ?

ការវះពិនិត្យសព (ដែលស្គាល់ផងដែរថាជាការពិនិត្យស្រាវជ្រាវរកមូលហេតុនៃការបាត់បង់ជីវិត) គឺជាការពិនិត្យមួយជំហានម្តងៗនៃផ្នែកខាងក្រៅសាកសព និង សរីរាង្គខាងក្នុង[1] ដោយវេជ្ជបណ្ឌិតម្នាក់ដែលហៅថាអ្នករោគសាស្រ្ត ដែលមានការហ្វឹកហ្វឺនពិសេសនៅក្នុងកិច្ចការប្រភេទនេះ។ ការវះពិនិត្យសព ត្រូវបានធ្វើទៅ នៅក្នុងកន្លែងតំកល់សពមុនឈាបនកិច្ច តាមលក្ខណៈដែលមានការគោរព និង គិតគូរនូវបំណងរបស់គ្រួសារ។

គេវះបើកសពនេះ ដោយវះកាត់នៅទ្រូង ពោះ និងក្បាល ដើម្បីអាចដកយកសរីរាង្គចេញយកទៅពិនិត្យមើល។ ក្នុងអម្លុងការវះពិនិត្យសព គេកាត់យកសំណាកជាលិកាតូចៗ[2] ទៅពិនិត្យមើលនៅក្រោមអតិសុខុមទស្សន៍។

ជួនកាលទៅ ជាលិកានិងសរីរាង្គខ្លះរបស់សព តំរូវឲ្យមានការពិនិត្យឯកទេស ហើយវាអាចជាការចាំបាច់ក្នុងការរក្សាទុកសរីរាង្គទាំងមូល សំរាប់ការពិនិត្យលំអិតថែមទៀត។

នៅពេលបំពេញការវះពិនិត្យសពរួចហើយ គេបិទកន្លែងវះកាត់យ៉ាងហ្មត់ចត់ ហើយអាចមើលឃើញតែនៅពេលដែលសាកសពគ្មានគ្របអ្វីប៉ុណ្ណោះ។ ការមើលជាធម្មតានូវសពនេះ អាចធ្វើទៅនៅក្រោយពីការវះពិនិត្យសពហើយ។

## គំរោងពេលវេលាសំរាប់ការវះពិនិត្យសព

ការវះពិនិត្យសពត្រូវបានធ្វើឡើងយ៉ាងរហ័សទៅតាមលទ្ធភាព ក្រោយពីទទួលការអនុញ្ញាតពីអ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធ។ ជាធម្មតា ការវះពិនិត្យសពនេះនឹងធ្វើទៅក្នុងរង្វង់ពេល 48 ម៉ោង ក្រោយពីបាត់បង់ជីវិតហើយ។

---

[1] សរីរាង្គមួយ គឺជាការប្រមូលផ្តុំនៃជាលិកាផ្សេងៗ ដែលបង្កើតជាទំរង់ពិសេសមួយនៅក្នុងរាងកាយ ហើយបំពេញមុខងារពិសេស ឧទាហរណ៍៖ បេះដូង, ខួរក្បាល, ថ្លើម, តម្រងម៉ូត្រ។

[2] ជាលិកាគឺជាផ្នែកតូចមួយ (កំរាស់ប្រហែល 0,5 សង់ទីម៉ែត្រ) ដែលជាធម្មតាត្រូវបានយកចេញ ហើយរៀបចំសំរាប់ការពិនិត្យនៅក្រោមអតិសុខុមទស្សន៍។

# តើអ្វីទៅដែលជាប្រយោជន៍នៃ ការវះពិនិត្យសព ?

ការវះពិនិត្យសពនឹងផ្តល់ព័ត៌មានលំអិតអំពីមូលហេតុអ្វីទៅដែលបានបណ្តាលឲ្យអ្នកនោះស្លាប់។ ទោះបីជាមូលហេតុនៃការបាត់បង់ជីវិតនេះទំនងជាច្បាស់លាស់ក្តី ក៏អ្នកនោះអាចមានបញ្ហារោគមួយ ដែលគេមិនបានដឹងក្នុងអម្លុងពេលមានជីវិតដែរ។

ការវះពិនិត្យសពអាចរកមើលដឹងដំបៅដែលមិនបានធ្វើរោគវិនិច្ឆ័យ រោគមហារីក ការស្ទះសរសៃឈាម លក្ខណៈមិនធម្មតានៃពន្ធុ ឬផលវិបាកនៃការព្យាបាល។ ព័ត៌មាននេះអាចជាការសំខាន់ណាស់សំរាប់សុខភាពនៅថ្ងៃមុខរបស់សមាជិកផ្សេងទៀតនៃគ្រួសារ ហើយដើម្បីជួយគេឲ្យយល់ដឹងរឿងពិតនៃការបាត់បង់ជីវិតនោះ។

# នរណាទៅដែលសំរេចថា គួរតែមានការវះពិនិត្យសពនោះ?

## ការវះពិនិត្យសពដើម្បីស៊ើបអង្កេត

ការបាត់បង់ជីវិតនៅក្នុងមន្ទីរពេទ្យ ត្រូវរាយការណ៍ជូនអ្នកស៊ើបអង្កេតអំពីមរណភាព បើការបាត់បង់ជីវិតនេះបានកើតមានឡើងតាមរបៀបដូចតទៅនេះ ៖

- ក្នុងរង្វង់ពេល 24 ម៉ោងនៃការចូលព្យាបាលនៅក្នុងមន្ទីរពេទ្យ (បើគេយល់ថាមរណភាពនេះមិនមែនដោយសារមូលហេតុធម្មជាតិទេនោះ),
- បើមរណភាពនេះកើតមានឡើងក្នុងអម្លុងនៃទំរង់ការចាក់ថ្នាំសណ្តំ ឬ ក្នុងរង្វង់ពេល 24 ម៉ោង បន្ទាប់ពីអ្នកនោះបានចាក់ថ្នាំសណ្តំហើយ,
- បើនរណាមួយត្រូវបានបញ្ជាក់ដោយវេជ្ជបណ្ឌិតថា “ស្លាប់នៅពេលទៅដល់” មន្ទីរពេទ្យ។

កាលៈទេសៈឯទៀតដែលគេត្រូវរាយការណ៍មរណភាពទៅកាន់អ្នកស៊ើបអង្កេតអំពីមរណភាព មានរួមទាំងការស្លាប់ដោយសារមូលហេតុមិនធម្មតា គួរឲ្យសង្ស័យ ឬ មិនអាចដឹងបាន ឬដោយគ្មានរំពឹងទុកជាមុន។ មូលហេតុទាំងនេះអាចមានរួមទាំងការវាយដំ គ្រោះថ្នាក់ និងការសម្លាប់ខ្លួន។ មរណភាពនៅក្នុងស្ថានការណ៍ផ្សេងខ្លះទៀតដូចជាស្លាប់នៅក្នុងមន្ទីរឃុំឃាំង និងការបាត់បង់ជីវិតខ្លះនៅក្នុងស្ថាប័នទាំងឡាយ ក៏ត្រូវតែរាយការណ៍ផងដែរ។

ការជាប់ទាក់ទងរបស់អ្នកស៊ើបអង្កេតអំពីមរណភាព មិនចាំបាច់តែកើតមានឡើង ដោយសារតែមានការសង្ស័យណាមួយអំពីការបាត់បង់ជីវិតនោះទេ។ តួនាទីរបស់អ្នកស៊ើបអង្កេតអំពីមរណភាព គឺដើម្បីកំណត់មូលហេតុនិងកាលៈទេសៈនៃការបាត់បង់ជីវិត។

បើអ្នកស៊ើបអង្កេតអំពីមរណភាពធ្វើសំណូមពរឲ្យធ្វើការវះពិនិត្យសព នោះគេមិនចាំបាច់ឲ្យមានការអនុញ្ញាតពីគ្រួសារសំរាប់ការវះពិនិត្យសពសំរាប់ស៊ើបអង្កេតទេ ប៉ុន្តែការជំរាបគ្រួសាររបស់សពឲ្យដឹង គឺជាការដ៏សំខាន់។

កូនសៀវភៅនេះផ្តល់ព័ត៌មានអំពីការវះពិនិត្យសពដោយមន្ទីរពេទ្យ (មិនមែនសំរាប់ស៊ើបអង្កេត)តែប៉ុណ្ណោះ។ ដើម្បីទទួលព័ត៌មានបន្ថែមអំពីការវះពិនិត្យសពសំរាប់ស៊ើបអង្កេត សូមទាក់ទងបុគ្គលិកសង្គមកិច្ចនៅ State Coroners' Office (ការិយាល័យរដ្ឋនៃអ្នកស៊ើបអង្កេតអំពីមរណភាព) ដោយទូរស័ព្ទទៅលេខ (08) 8204 0600 ។

## ការវះពិនិត្យសពដោយមន្ទីរពេទ្យ

គ្រួសារនៃសពអាចសុំឲ្យវេជ្ជបណ្ឌិតរៀបចំធ្វើការវះពិនិត្យសព ឬមួយវេជ្ជបណ្ឌិតអាចសុំការអនុញ្ញាតពីគ្រួសារដើម្បីធ្វើការវះពិនិត្យសព ដើម្បីជួយរកមើលមូលហេតុដែលជននោះស្លាប់។

មន្ទីរពេទ្យមិនអាចវះពិនិត្យសពដោយមិនបានស្វែងរកការអនុញ្ញាតពីគ្រួសារនោះឡើយ។

បុគ្គលិកមន្ទីរពេទ្យនឹងគោរពហើយគាំទ្រសេចក្តីសំរេចចិត្តណាក៏ដោយដែលធ្វើដោយអ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធ អំពីការវះពិនិត្យសពដោយមន្ទីរពេទ្យ។

# នរណាទៅដែលផ្តល់ការអនុញ្ញាតសំរាប់ការវះពិនិត្យសព ?

អ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធ គឺជាអ្នកដែលគេនឹងសុំឲ្យផ្តល់ការអនុញ្ញាតឲ្យធ្វើការវះពិនិត្យសព។ អ្នកនោះនឹងត្រូវចុះហត្ថលេខាលើពាក្យសំណូមពរវះពិនិត្យសព និងសេចក្តីអនុញ្ញាតមួយ។

នៅតាមលំដាប់នៃអាទិភាព  អ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធ គឺ :

- ដៃគូ  កូនដែលមានអាយុលើសពី 18 ឆ្នាំ  ម្តាយឬឪពុក  បងប្អូនបង្កើតដែលមានអាយុលើសពី 18 ឆ្នាំ។

បើកុមារម្នាក់ស្លាប់  អ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធ តាមលំដាប់អាទិភាព គឺ :

- ម្តាយឬឪពុក  បងបង្កើតដែលមានអាយុ 18 ឆ្នាំឡើងទៅ  អាណាព្យាបាលនៃកុមារនោះ។

ពាក្យសំណូមពរវះកាត់ពិនិត្យសពនិងសេចក្តីអនុញ្ញាតមួយច្បាប់ នឹងប្រគល់ទៅឲ្យអ្នកផ្តល់ការអនុញ្ញាតនេះ។

បើលោកអ្នកមានសំណួរណាមួយអំពីដំណើរការនេះ  លោកអ្នកគួរពិភាក្សាសំណួរទាំងនេះជាមួយបុគ្គលិកពេទ្យដែលស្នើសុំការអនុញ្ញាតសំរាប់ការវះពិនិត្យសព។

# តើមានជម្រើសផ្សេងពីការវះពិនិត្យសព ទាំងស្រុងឬទេ ?

នៅពេលដែលលោកអ្នកផ្តល់ការអនុញ្ញាតឲ្យធ្វើការវះពិនិត្យសព  លោកអ្នកអាចសំរេចថា តើលោកអ្នកចង់បានការវះកាត់ពិនិត្យសពទាំងស្រុង ឬក៏ការវះពិនិត្យសពដែលមាន កំរិតកំណត់។

ការវះពិនិត្យសពទាំងស្រុង ជាប់ពាក់ព័ន្ធនឹងការពិនិត្យយ៉ាងលំអិតនៃសរីរាង្គខាងក្នុង ទាំងអស់ ដោយមានរួមទាំងខួរក្បាល  បេះដូង  សួត  ថ្លើម  តម្រងម៉ូត្រ  ពោះវៀន  ក្រពះ សរីរាង្គបន្តពូជ  សរសៃឈាម  និងក្រពេញតូចទាំងពួង។

លោកអ្នកអាចចង់ផ្តល់ការអនុញ្ញាតឲ្យវះពិនិត្យសព ដោយមានកំរិតកំណត់តែប៉ុណ្ណោះ។ លោកអ្នកនឹងត្រូវចង្អុលបង្ហាញនៅលើពាក្យសំណូមពរវះពិនិត្យសព និងសេចក្តីអនុញ្ញាត នូវផ្នែកឬកន្លែងរាងកាយដែលលោកអ្នកមិនចង់ឲ្យពិនិត្យមើល។ ទង្វើនេះនឹងដាក់កំរិត កំណត់ទៅលើពត៌មានដែលទទួលបាន  ប៉ុន្តែនឹងនៅតែជាទំរង់ការដ៏មានតម្លៃដែរ។ មន្ទីរពេទ្យនឹងធ្វើតាមតាមសេចក្តីប្រាថ្នារបស់លោកអ្នក។

លោកអ្នកអាចពិភាក្សាបញ្ហានេះជាមួយនឹងបុគ្គលិកមន្ទីរពេទ្យ ដែលនិយាយទៅកាន់ លោកអ្នកអំពីការវះពិនិត្យសព។

# តើមានលទ្ធភាពធ្វើអំណោយសរីរាង្គ ឬ ជាលិកាសំរាប់ការវះកាត់ផ្សាំឬទេ ?

មនុស្សជាច្រើនបានចង្អុលបង្ហាញនូវបំណងរបស់គេក្នុងការធ្វើជាអ្នកផ្តល់អំណោយសរីរាង្គ ក្រោយពីបាត់បង់ជីវិត។ អ្នកនោះប្រហែលជាបានធ្វើយ៉ាងនេះ ដោយចុះឈ្មោះនៅក្នុង Australian Organ Donor Registry (បញ្ជីអ្នកផ្តល់អំណោយសរីរាង្គអូស្ត្រាលី) ដោយប្រាប់ឲ្យដឹងនូវសេចក្តីប្រាថ្នាធ្វើអំណោយរបស់គេ នៅលើប័ណ្ណបើកបររថយន្ត ឬ ដោយគ្រាន់តែប្រាប់សមាជិកគ្រួសារម្នាក់។ មិនមែនការបាត់បង់ជីវិតទាំងអស់នឹងផ្តល់ស្ថានភាពត្រឹមត្រូវសំរាប់ធ្វើអំណោយសរីរាង្គនោះទេ។ វាជាការសំខាន់ណាស់ក្នុងការគោរពទៅតាមសេចក្តីប្រាថ្នាទាំងនេះ នៅពេលមានលទ្ធភាពធ្វើទៅបាន។

គេអាចសួរលោកអ្នកអំពីការធ្វើអំណោយសរីរាង្គសំរាប់ការវះកាត់ផ្សាំ។ បុគ្គលិកមួយរូបមកពី SA Organ Donation Agency (អង្គការធ្វើអំណោយសរីរាង្គ) នឹងពិភាក្សារាល់ចំណុចទាំងអស់នៃការធ្វើអំណោយសរីរាង្គនិងការវះកាត់ផ្សាំ ជាមួយនឹងគ្រួសារសព។ មន្ទីរពេទ្យក៏អាចរៀបចំឲ្យមានអ្នកពិគ្រោះផ្តល់ឱវាទមួយរូប ដើម្បីពិភាក្សាបញ្ហាណាមួយដែលលោកអ្នកអាចមានផងដែរ។

ពត៌មានបន្ថែមទៀត មាននៅឯ SA Organ Donation Agency ដោយទូរស័ព្ទទៅលេខ 8207 7117 (ឬមួយមន្ទីរពេទ្យមានពត៌មានសំរាប់ទាក់ទងនៅក្រោយពេលម៉ោងធ្វើការ)។

# តើមានការរក្សាទុកសរីរាង្គឬជាលិកាណាមួយក្រោយពីការវះពិនិត្យសពឬទេ?

នៅពេលបំពេញការវះពិនិត្យសពរួចហើយ សរីរាង្គទាំងពួងនឹងត្រូវដាក់បញ្ចូលទៅក្នុងសពវិញ បើមិនត្រូវការធ្វើតេស្តបន្ថែមទៀតទេនោះ។ គេអាចយកជាលិកាហើយជូនកាលទៅសរីរាង្គទាំងមូល ទៅពិនិត្យថែមទៀតដើម្បីឲ្យគេអាចធ្វើរោគវិនិច្ឆ័យពេញលេញ។ គេនឹងត្រូវការសេចក្តីអនុញ្ញាតពីអ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធ សំរាប់ការរក្សាទុកសរីរាង្គ ដើម្បីធ្វើតេស្តថែមទៀត។ សរីរាង្គដែលបានត្រូវរក្សាសំរាប់ធ្វើតេស្តថែមទៀត អាចដាក់បញ្ចូលទៅក្នុងសពវិញ នៅពេលធ្វើតេស្តរួចហើយ។

## សរីរាង្គឬជាលិកាដែលរក្សាទុកសំរាប់ការស្រាវជ្រាវនិងការសិក្សាអប់រំ

ការរក្សាទុកនិងប្រើជាលិកានិងសរីរាង្គសំរាប់ការស្រាវជ្រាវឬការសិក្សាអប់រំ និងហ្វឹកហ្វឺនតម្រូវឲ្យមានការអនុញ្ញាត។ ការអនុញ្ញាតនេះអាចជាសំណូមពរសំរាប់គំរោងការងារស្រាវជ្រាវ ដែលយល់ព្រមដោយគណៈកម្មាធិការសីលធម៌មន្ទីរពេទ្យ សំរាប់គោលបំណងបង្រៀន ដោយមានរួមទាំងការប្រើប្រាស់នៃសារមន្ទីរវេជ្ជសាស្រ្ត ឬសំរាប់ការពិភាក្សារវាងវេជ្ជបណ្ឌិតឯកទេសទាំងឡាយ។

អ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធ អាចដកយកចេញនូវការអនុញ្ញាតរបស់គេនៅពេលណាមួយក៏បានដែរ ដោយទាក់ទងបុគ្គលិកមន្ទីរពេទ្យ ដែលបាននិយាយទៅកាន់គេ អំពីការវះពិនិត្យសព ឬ ដោយសរសេរទៅកាន់ Chief Executive Officer របស់មន្ទីរពេទ្យ។

# តើអ្វីទៅដែលជាជម្រើសសំរាប់ការប្រគល់មកវិញឬការបោះចោលសរីរាង្គ ?

នៅពេលដែលលោកអ្នកផ្តល់ការអនុញ្ញាតឲ្យធ្វើការវះពិនិត្យសព លោកអ្នកនឹងត្រូវការសំរេចនូវអ្វីទៅដែលនឹងកើតមានឡើងចំពោះសរីរាង្គនិងជាលិកាទាំងពួង នៅពេលដែលបានបំពេញសព្វគ្រប់នូវតេស្តទាំងអស់ហើយ។

លោកអ្នកនឹងមានជំរើសមួយចំនួន ដោយមានរួមទាំងថាតើសរីរាង្គនិងជាលិកាទាំងនេះ គួរ :

- បោះចោលដោយមន្ទីរពេទ្យ (ជាធម្មតា ការបោះចោលនេះនឹងធ្វើឡើងតាមរយៈការដុត), ឬ
- ដាក់បញ្ចូលទៅក្នុងសពវិញ មុនពេលពិធីឈាបនកិច្ច (យ៉ាងណាមិញ ទង្វើនេះអាចពន្យារពេលឈាបនកិច្ច ហើយជួនកាលទៅ គេមានការលំបាកក្នុងការប្រាប់ជាមុននូវរយៈពេលត្រូវរង់ចាំ), ឬ
- ប្រគល់ទៅឲ្យអ្នកចាត់ចែងពិធីឈាបនកិច្ចសំរាប់បញ្ចុះសព ដោយយោងទៅតាមសេចក្តីប្រាថ្នារបស់គ្រួសារ។

# តើខ្ញុំស្វែងដឹងនូវលទ្ធផលនៃការវះពិនិត្យសព តាមរបៀបណា ?

អ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធ អាចសំរេចពិភាក្សាលទ្ធផលនៃការវះពិនិត្យសព ជាមួយនឹងវេជ្ជបណ្ឌិតដែលទទួលខុសត្រូវចំពោះការថែទាំអ្នកស្លាប់។ ជំរើសផ្សេងពីនេះ គឺថា អ្នកពេញវ័យដែលជាសាច់ញាតិជិតស្និទ្ធអាចសំរេចឲ្យវេជ្ជបណ្ឌិតពិនិត្យរោគទូទៅ (GP) ម្នាក់ ទទួលលទ្ធផលនៃការវះពិនិត្យសពនេះ ហើយពិភាក្សាលទ្ធផលទាំងឡាយ ជាមួយនឹងគេ។

មន្ទីរពេទ្យក៏មានរបាយការណ៍វះពិនិត្យសពដែលមានពាក្យសាមញ្ញផងដែរ បើសិនជាមាន សំណូមពរ។

បើអ្នកស៊ើបអង្កេតអំពីមរណភាពរដ្ឋជាអ្នកវះពិនិត្យសព  នោះអ្នកពេញវ័យដែលជា សាច់ញាតិជិតស្និទ្ធ នឹងត្រូវទាក់ទងនឹងការិយាល័យរបស់អ្នកស៊ើបអង្កេតអំពីមរណភាព តាមទូរស័ព្ទលេខ 8204 0600  ដើម្បីទទួលពត៌មានបន្ថែម អំពីរបាយការណ៍វះ ពិនិត្យសពនេះ។

# តើការរៀបចំពិធីឈាបនកិច្ច អាចធ្វើទៅនៅពេលណា ?

លោកអ្នកគួរទាក់ទងអ្នកចាត់ចែងពិធីឈាបនកិច្ចឲ្យបានរហ័សទៅតាមលទ្ធភាព ក្រោយពីមរណភាព ហើយអ្នកចាត់ចែងនេះនឹងទាក់ទងមន្ទីរពេទ្យអំពីការបញ្ចេញសព។

បើលោកអ្នកសំរេចថា ការវះពិនិត្យសពដោយមន្ទីរពេទ្យគួរតែធ្វើឡើង នោះសពរបស់អ្នកស្លាប់នឹងត្រូវបញ្ចេញទៅឲ្យអ្នកចាត់ចែងពិធីឈាបនកិច្ច ជាធម្មតាគឺនៅក្នុងពេលពីរឬបីថ្ងៃ ក្រោយពីមរណភាព (យ៉ាងណាមិញអម្លុងពេលនេះអាចយូរជាងនោះ បើមរណភាពបានកើតមានឡើងក្នុងពេលចុងអាទិត្យ ឬថ្ងៃឈប់សំរាកសាធារណៈ)។ បន្ថែមពីលើនេះទៅទៀតនោះ បើមានសេចក្ដីសំរេចឲ្យបញ្ជូលសរីរាង្គទៅក្នុងសពវិញ នោះពិធីឈាបនកិច្ចអាចត្រូវបានពន្យារពេល។ វាជាការលំបាកក្នុងការប្រាប់ឲ្យដឹងមុន នូវរយៈពេលដែលនឹងត្រូវការរង់ចាំដោយសារតែទង្វើនេះ។

អ្នកចាត់ចែងពិធីឈាបនកិច្ចត្រូវបានប្រើដើម្បីធ្វើសហការជាមួយនាយកដ្ឋានតំកល់សពដើម្បីធ្វើទៅតាមសេចក្ដីត្រូវការនៃគ្រួសារដែលមានសេចក្ដីសោកសង្រេង។ ឧទាហរណ៍ៈ ការវះពិនិត្យសពនឹងមិនជ្រៀតជ្រែកដល់សេចក្ដីប្រាថ្នាណាមួយ ដើម្បីអប់សពនោះឡើយ។

# តើលោកអ្នកអាចទទួលជំនួយអ្វីខ្លះទៅ ?

## ជំនួយវប្បធម៌ និង សាសនា

ការវះពិនិត្យសពបានអនុវត្តចំពោះអ្នកបាត់បង់ជីវិតទាំងឡាយ ដែលមកពីសាវតារវប្បធម៌និងសាសនាផ្សេងៗគ្នាជាច្រើន។ បើលោកអ្នកដឹងអំពីការអនុវត្ត / ជំនឿវប្បធម៌ឬសាសនាណាមួយដែលគួរគោរពក្នុងអំឡុងដំណើរការវះពិនិត្យសព នោះវាជាការសំខាន់ណាស់ដែលលោកអ្នកប្រាប់បុគ្គលិកឲ្យដឹង។

បើលោកអ្នកមានសំណួរណាមួយ សូមនិយាយទៅកាន់នរណាមួយដែលអាចផ្តល់ជូនលោកអ្នកនូវជំនួយវប្បធម៌និងសាសនា។ បុគ្គលិកមន្ទីរពេទ្យអាចជួយលោកអ្នក ក្នុងការទាក់ទងជនសមរម្យ។

## ពត៌មានជាភាសាផ្សេងទៀត

កូនសៀវភៅនេះមានជាភាសាផ្សេងទៀតផងដែរ។ បុគ្គលិកមន្ទីរពេទ្យអាចជួយលោកអ្នកដើម្បីឲ្យទទួលកូនសៀវភៅនេះមួយច្បាប់ ឬក៏រៀបចំឲ្យមានសេវាកម្មបកប្រែភាសាដើម្បីជួយលោកអ្នក នៅពេលដែលចាំបាច់។

## វត្ថុអនុស្សាវរីយ៍

នៅពេលដែលធ្វើការវះពិនិត្យសពទារកមួយ ជាធម្មតាបុគ្គលិកត្រូវរៀបចំកញ្ចប់អនុស្សាវរីយ៍មួយ។ កញ្ចប់នេះអាចមានរួមទាំងរូបថត ស្នាមប្រអប់ជើងនិងប្រអប់ដៃ ផ្លាកឈ្មោះ និងសក់ បើមានលទ្ធភាពធ្វើទៅបាន។ កញ្ចប់អនុស្សាវរីយ៍នេះ អាចរក្សាទុកក្នុងពេលមួយរយៈកាល ក្រោយពីទារកបានស្លាប់ហើយ។ យ៉ាងណាមិញ គ្រួសារទាំងឡាយគួរប្រមូលកញ្ចប់អនុស្សាវរីយ៍នេះឲ្យបានរហ័សទៅតាមលទ្ធភាព ក្រោយពីការវះពិនិត្យសពទារកហើយ។

បើលោកអ្នកមិនចង់ឲ្យមានការវះពិនិត្យសព ប៉ុន្តែចង់ឲ្យមានកញ្ចប់អនុស្សាវរីយ៍សំរាប់ទារកលោកអ្នក នោះគេអាចរៀបចំធ្វើបាន។

សូមនិយាយទៅកាន់បុគ្គលិកមន្ទីរពេទ្យ ដើម្បីទទួលពត៌មានបន្ថែម។

## ពត៌មាន និង ជំនួយសំរាលការសោកសង្រេង

បើលោកអ្នកមានសំណួរណាមួយ បុគ្គលិកមន្ទីរពេទ្យឬនាយកដ្ឋានរោគសាស្រ្ត នឹងព្យាយាមឆ្លើយនឹងសំណួរទាំងនោះជូនលោកអ្នក។ មន្ទីរពេទ្យអាចជួយលោកអ្នកដើម្បីឲ្យទទួលជំនួយសំរាលការសោកសង្រេង នៅពេលធ្វើសំណូមពរវះពិនិត្យសព។ សេវាកម្មនេះនឹងអាចជួយលោកអ្នកលើបញ្ហាផ្ទាល់ខ្លួននិងបញ្ហាប្រតិបត្តិផ្សេងៗ។

បុគ្គលិកមន្ទីរពេទ្យក៏អាចផ្តល់ជូនលោកអ្នកនូវឯកសារនិពន្ធ និងពត៌មានសំរាប់ទាក់ទងក្រុមជំនួយផ្សេងៗយ៉ាងច្រើន ដែលមានសំរាប់ជួយលោកអ្នក ក្នុងការដោះស្រាយសេចក្តីសោកសង្រេងរបស់លោកអ្នកផងដែរ។

លេខបោះផ្សាយ៖ DHS_0021_ArtBerries_Hyde Park Press_ACCS_August 2002